មនសិការខ្មែរ
Monoaksekar Khmer

ថ្ងៃសៅរ៍-អាទិត្យ ទី៤-៥ ខែសីហា ឆ្នាំ២០០៧

Ven. Tim Sakhom has been arrested by Vietnamese authority allegegdly entering the country illegally

# ព្រះតេជគុណ ទឹម សាខន ត្រូវបានអាជ្ញាធរយួនចាប់ដាក់គុកដោយចោទប្រកាន់ពីបទឆ្លងដែនខុសច្បាប់

ដោយ : មុត ស្រួច

ការបាត់ខ្លួន ព្រះតេជគុណ *ទឹម សាខន* ចាប់តាំងពីពេលដែលព្រះអង្គត្រូវគេចាប់ផ្សឹកតាមបញ្ជា របស់សម្ដេចសង្ឃរាជ *ទេព វង្ស* និងសម្ដេចសង្ឃនាយក *នន់ ង៉ែត* កាលពីថ្ងៃទី៣០ ខែមិថុនា បណ្ដាលឱ្យមានការស្វែងរក និងចោទឆ្លើយឆ្លងគ្នាយ៉ាងគងរំពងរហូតមកនោះ គឺទើបនឹងទទួលបានព័ត៌មានច្បាស់នៅថ្ងៃព្រហស្បតិ៍ ទី០២ ខែសីហា ឆ្នាំ២០០៧កន្លងទៅថា ព្រះតេជគុណ *ទឹម សាខន* ត្រូវបានអាជ្ញាធរយួនចាប់ដាក់គុកហើយ ដោយចោទប្រកាន់ថា ឆ្លងដែនខុសច្បាប់ ។

តាមប្រភពព័ត៌មានពីវិទ្យុយួន "*គីនតេ*" គេបានផ្សាយថា ដោយទទួលបានរបាយការណ៍ពីកងកម្លាំងល្បាតព្រំដែន អង្គភាពការពារច្បាប់ របស់វៀតណាម បានដំណើរការត្រួតពិនិត្យ និងឃាត់ខ្លួនជនម្នាក់ដែលចូលស្រុកដោយខុសច្បាប់ ។

វិទ្យុយួនដដែលនេះ ផ្សាយបន្តទៀតថា ក្រោយការឃុំខ្លួនជាបណ្ដោះអាសន្ន ជននេះបានសារភាពថា ឈ្មោះ *ទឹម សាខន* កើតនៅឆ្នាំ១៩៦៨ នៅឃុំបាជុក ស្រុកទ្រីតូង ខេត្តអានយ៉ាង បានឆ្លងដែនចូលកម្ពុជា ដោយខុសច្បាប់ ហើយរស់នៅនិងស្លៀកពាក់ត្រៃចីវរ ជាព្រះសង្ឃខ្មែរ ។

វិទ្យុយួន "*គីនតេ*" បានផ្សាយតាមរបៀបឡប់ឡែ ថា ថ្ងៃទី៣០ មិថុនា ២០០៧ ដោយសារតែរំលោភវិន័យ សាសនា ត្រូវបាន "*ក្រុមប្រឹក្សាព្រះសង្ឃពុទ្ធសាសនាមជ្ឈិមចាប់ផ្សឹក*" បានជាគាត់រកវិធីត្រឡប់ទៅវៀតណាមវិញ ។

ជាមួយគ្នានេះដែរ គេថា ព្រះតេជគុណ *ទឹម សាខន* បានសារភាពថា ក្នុងពេលស្ថិតនៅកម្ពុជា មានអង្គការ និងបុគ្គលមួយចំនួន ជាជនជាតិវៀតណាមកំណើតខ្មែរប្រតិកិរិយានិរទេសខ្លួន បានប្រើប្រាស់ ហើយនាំគាត់ឱ្យចូលរួមក្នុងចលនា "*សហព័ន្ធខ្មែរកម្ពុជាក្រោមពិភពលោក*" និងភ្ជាប់ទំនាក់ទំនងផ្ដត់ផ្ដង់ឯកសារ កាសែត ប្រកាស ដើម្បីធ្វើសកម្មភាពឃោសនា ប្រឆាំងវៀតណាម ។

ក្នុងនោះគេបានចោទ ព្រះ

សកម្មភាពឃោសនា ប្រឆាំង វៀតណាម ។

ក្នុងនោះគេបានចោទ ព្រះ

តេជគុណ *ទឹម សាខន* ថា ព្រះអង្គបានជួបជាមួយ ខ្មែរកម្ពុជាក្រោមខ្លះ ដែលគ្រងត្រៃចីវរនៅកម្ពុជា តែងតែចាត់តាំងការប្រជុំបង្កចលាចល, ធ្វើបាតុកម្មមូលបង្កាច់ ប្រឆាំងវៀតណាម ដើម្បីញុះញង់ប្រមូលផ្ដុំគ្នាបង្កចលាចល បង្កបង្កើតលេសផ្សេងៗមូលបង្កាច់ថា រដ្ឋអំណាចវៀតណាម គាបសង្កត់ពលរដ្ឋខ្មែរ ។

វិទ្យុយួន "*គីនតេ*" បានផ្សាយនៅឃ្លាចុងក្រោយថា *ទឹម សាខន ត្រូវអង្គភាពការពារច្បាប់របស់វៀតណាមឃុំឃាំងជាបណ្ដោះអាសន្ន តាមមាត្រា៨៧ នៃច្បាប់ព្រហ្មទណ្ឌសាធារណរដ្ឋសង្គមនិយមវៀតណាមឆ្នាំ១៩៩៩ ដើម្បីវិនិច្ឆ័យនៅចំពោះមុខច្បាប់ស្ដីពីទោសបំផ្លិចបំផ្លាញគោលនយោបាយសាមគ្គីភាព*" ។

ការផ្សាយ របស់វិទ្យុយួនស្ដីពីការចាប់ព្រះតេជគុណ *ទឹម សាខន* ដាក់គុកនេះ បានធ្វើឱ្យលោក *ថាច់ សេដ្ឋា* ប្រធាន

សហគមន៍ខ្មែរកម្ពុជាក្រោម បញ្ចេញប្រតិកម្មភ្លាមៗថា រដ្ឋាភិបាលត្រូវតែទទួលខុសត្រូវទាំងស្រុងក្នុងរឿងនេះ។

លោក *ថាច់ សេដ្ឋា* បានថ្លែងយ៉ាងដូច្នេះថា "*សំខាន់គឺយើងទាមទារយកមកវិញ ហើយយើងរកមេធាវីដើម្បីប្តឹង ចាត់វិធានការចំពោះអ្នកដែលរំលោភលើរដ្ឋធម្មនុញ្ញដ៏ធ្ងន់ធ្ងរ ដោយយកប្រជារាស្ត្រខ្មែរឯង ទៅឱ្យបារទេសដាក់ទោសបែបនេះ*"។

ក្នុងនោះសហគមន៍ខ្មែរកម្ពុជាក្រោម ក៏បានចេញសេចក្តីថ្លែងការណ៍មួយ កាលពីថ្ងៃទី០២ ខែសីហា ឆ្នាំ២០០៧ ដោយបានសង្កត់ធ្ងន់ថា ប្រការដែលអាជ្ញាធរវៀតណាមចោទប្រកាន់ព្រះតេជគុណ *ទីម សាខន* ឆ្លងដែនចូលប្រទេសវៀតណាមដោយខុសច្បាប់នោះ គឺអាចបញ្ជាក់បានថា ព្រះតេជគុណ *ទីម សាខន* ជាពលរដ្ឋខ្មែរយ៉ាងពិតប្រាកដ។ ដូច្នេះរដ្ឋាភិបាលខ្មែរមានកាតព្វកិច្ចការពារ ពលរដ្ឋខ្មែរ ស្របតាមរដ្ឋធម្មនុញ្ញ និងច្បាប់សញ្ជាតិ ដែលកំពុងស្ថិតនៅជាធរមាន។

ក្នុងនោះ សហគមន៍ខ្មែរកម្ពុជាក្រោមបានដាក់ជាសំណួរថា តើនរណាមួយ ឬអង្គភាពណាមួយ ដែលជាអ្នកទទួលខុសត្រូវចំពោះការចាប់ បញ្ជូនខ្លួនព្រះតេជគុណ *ទីម សាខន* ទៅឱ្យអាជ្ញាធរវៀតណាម ?

សហគមន៍ខ្មែរកម្ពុជាក្រោម បានទាមទារឱ្យបញ្ជូនខ្លួន ព្រះតេជគុណ *ទីម សាខន* មកកាន់ប្រទេសកម្ពុជា ហើយត្រូវតែបើកការស៊ើបអង្កេតយ៉ាងលម្អិត ចំពោះករណីចាប់បញ្ជូនខ្លួនព្រះតេជគុណ *ទីម សាខន* និងលិខិតស្នើសុំទៅវៀតណាម របស់ព្រះតេជគុណ *ទីម សាខន* នោះផង ដើម្បីរកមុខរកជនល្មើសរំលោភរដ្ឋធម្មនុញ្ញ យកមកផ្តន្ទាទោសតាមច្បាប់។

ដោយឡែកលោក *យ៉ឹម សុវណ្ណ* អ្នកតំណាងរាស្ត្រគណបក្សសមរង្ស៊ី និងជាប្រធានគណៈកម្មការមហាផ្ទៃ ការពារជាតិ អង្កេត បោសសំអាត និងមុខងារសាធារណៈ របស់រដ្ឋសភា បានមានប្រសាសន៍យ៉ាងម៉ឺងម៉ាត់ថា លោកមិនអាចទទួលយកបានទេចំពោះទង្វើបែបនេះ។

លោក *យ៉ឹម សុវណ្ណ* បានសង្កត់ធ្ងន់ថា "*នេះជាករណីរំលោភសិទ្ធិធ្ងន់ធ្ងរណាស់ ហើយក្រសួងមហាផ្ទៃ និងរដ្ឋាភិបាលកម្ពុជា ជាអ្នកទទួលខុសត្រូវទាំងស្រុង*"។ ក្នុងនោះលោក *ខៀវ កាញារីទ្ធ* រដ្ឋមន្ត្រីក្រសួងព័ត៌មាន និងជាអ្នកនាំពាក្យរដ្ឋាភិបាលកម្ពុជា បានអះអាងថា *ទីម សាខន* ខុសឆ្គងត្រឹមតែធម្មវិន័យ ពុំមានអ្វីដែលត្រូវបញ្ជូនទៅប្រទេសវៀតណាមឡើយ។ លោកបានបន្តទៀតថា ការចោទប្រកាន់របស់វៀតណាមថា *ទីម សាខន* ឆ្លងដែនខុសច្បាប់នោះ គឺត្រូវមើលថា *ទីម សាខន* កាន់អត្តសញ្ញាណប័ណ្ណជនជាតិវៀតណាម ឬខ្មែរ។ ហើយបន្ទាប់មកទៀត រដ្ឋាភិបាលនឹងដោះស្រាយរឿងនេះតាមគោលការណ៍ច្បាប់។

ពុំមានប្រភពព័ត៌មានឯករាជ្យណាមួយ ហ៊ានអះអាងថា អាជ្ញាធរក្រុងភ្នំពេញ ហ៊ានទាមទារយកព្រះតេជគុណ *ទីម សាខន* ពីអាជ្ញាធរយួនមកវិញ ឬក៏អត់ទេ។ ម្យ៉ាងទៀត សហព័ន្ធខ្មែរកម្ពុជាក្រោមពិភពលោក ដែលមានមូលដ្ឋាននៅអាមេរិក ក៏កំពុងរៀបចំពាក្យបណ្តឹងប្តឹងអាជ្ញាធរក្រុងហាណូយ ទៅតុលាការអន្តរជាតិដែរ ចំពោះករណីព្រះតេជគុណ *ទីម សាខន* នេះ។

គេថា សម្តេចសង្ឃរាជ *ទេព វង្ស* និងសម្តេចសង្ឃនាយក *នន់ ង៉ែត* ដែលជាដើមចមនៅក្នុងរឿងចាប់ផ្សឹកព្រះសង្ឃ *ទីម សាខន* ដោយសារហេតុផលនយោបាយនោះ ហាក់ដូចជាពុំមានសង្ឃដីកាអ្វី ដែលត្រូវថ្វាថ្លែងទៀតទេ ព្រោះសាច់រឿងអាថ៌កំបាំង តាំងពីថ្ងៃទី៣០ ខែមិថុនា រហូតមកដល់ថ្ងៃទី០២ ខែសីហា ឆ្នាំ២០០៧ នេះ ត្រូវលាតត្រដាងអស់ទៅហើយ៕